# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាឧទ្ធរណ៍បាត់ដំបង**

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ ២៩៤

ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១

សាលដីកាព្រហ្មទណ្ឌ

លេខៈ ២៩៤ (ខ)

ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍បាត់ដំបង

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស០១៥/០៧១៤/រកម/ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ និងព្រះរាជក្រឹត្យលេខ នស/រកត/០២២០/១៩៨ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឲ្យដំណើរការសាលាឧទ្ធរណ៍តំបន់ បានបើកសវនាការជាសាធារណៈ នៅសាលសវនាការនៃសាលាឧទ្ធរណ៍បាត់ដំបង នាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ ដោយមានសមាសភាពដូចតទៅ ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

**ឯកឧត្តម** [redacted] **ប្រធានក្រុមប្រឹក្សា**

**លោក** [redacted] **ចៅក្រមប្រឹក្សា**

**លោក** [redacted] **ចៅក្រមប្រឹក្សា**

**តំណាងមហាអយ្យការ**

**លោក** [redacted] **ព្រះរាជអាជ្ញា**

**ក្រឡាបញ្ជីសវនាការ**

**លោក** [redacted]

ដើម្បីពិភាក្សាដេញដោលលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៩៤ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ ដែលមានៈ

-ជនជាប់ចោទឈ្មោះ [redacted] ឧត្តម ហៅ ហ្វុង ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅភូមិស្ពានកណ្តាល ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង សាសនាព្រះពុទ្ធ មុខរបរនៅផ្ទះ [redacted] ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ប្រពន្ធឈ្មោះ [redacted] ភ្លិច (លែងលះ) ឪពុកឈ្មោះ [redacted] ធន (រស់) ម្តាយឈ្មោះ [redacted] មួយ (រស់) កម្រិតវប្បធម៌ថ្នាក់ទី១២ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (ក្នុងឃុំ) (អ្នកប្តឹងឧទ្ធរណ៍)

-ឃុំខ្លួនតាមដីកាបង្គាប់ឲ្យចាប់ខ្លួន-ឃុំខ្លួន លេខៈ ១១៩០ ត.ព្រ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ របស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងខេត្តបាត់ដំបង ។ (ឃុំខ្លួនថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០)

ជាប់ចោទពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ប្រព្រឹត្តនៅចំណុចភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]សីហា ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ។

## ៦រឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង៤និង៣០នាទី ទាបភ្លឺ នៅចំណុចភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ជនជាប់ចោទឈ្មោះ [redacted] ឧត្តម ភេទប្រុស អាយុ ២១ឆ្នាំ បានធ្វើសកម្មភាពប៉ុនប៉ងរំលោភប្អូនថ្លៃស្រីរបស់ខ្លួនឈ្មោះ [redacted] គីមហុង អាយុ១៤ឆ្នាំ ដែលនាងកំពុងគេងនៅក្នុងបន្ទប់តែម្នាក់ឯង ព្រោះថាពេលនោះឪពុកម្តាយ និងជីដូន បានក្រោកទៅហែទានវស្សាអស់ ។ ដោយឃើញដូច្នេះ ឈ្មោះ [redacted] ឧត្តម បានចូលទៅក្នុងបន្ទប់ប្អូនថ្លៃឈ្មោះ [redacted] គីមហុង ពេលនាងកំពុងគេងលក់ហើយបានធ្វើសកម្មភាពសម្រាតខោអាវរបស់ប្អូនថ្លៃដល់ត្រឹមជង្គង់ ប៉ុន្តែត្រូវឈ្មោះ [redacted] គីមហុង ធាក់ចំប្រដាប់ភេទជនជាប់ចោទ និងរើបំរាស់ តែត្រូវឈ្មោះ [redacted] គីមហុង ខំរើបំរាស់ម្តងទៀត [redacted]ន ឧត្តម បណ្តាលឲ្យចុកហួល ហើយឈ្មោះ [redacted] ឧត្តម បានងើបដើរចេញ ដោយបានគំរាមថា បើប្រាប់ប៉ាម៉ាក់ឱ្យដឹងនឹងមានរឿងហើយ ។

**-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខៈ ១១៧២ ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖**

១-ផ្តន្ទាទោសដាក់ពន្ធនាគារលើ៖ ឈ្មោះ [redacted] ឧត្តម ហៅ ហុង ភេទប្រុស អាយុ២១ឆ្នាំ (មានសាវតារជាតិដូចខាងលើ) កំណត់រយៈពេល ០៨ឆ្នាំ(ប្រាំបីឆ្នាំ) គិតចាប់ពីថ្ងៃចាប់ខ្លួនបានយកមកអនុវត្តទោសក្នុងពន្ធនាគារ ពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុច ភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ ។

២-បង្គាប់មកជនជាប់ចោទឈ្មោះ [redacted] ឧត្តម ឲ្យសងសំណងជំងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦០,០០០,០០០រៀល(ហុកសិបលានរៀល) ការទាមទារលើសពីនេះ ត្រូវបដិសេធចោល ។

៣-ចេញដីកាបង្គាប់ឲ្យចាប់ខ្លួន៖ ឈ្មោះ [redacted] ឧត្តម តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ ត្រូវនឹងថ្ងៃចន្ទ ៤កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ឧត្តម ហៅ ហុង ចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted]សីហា ។

ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ តាមការកំណត់នៃច្បាប់ ។

-បានឃើញៈ ពាក្យបណ្ដឹងទាស់ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ របស់លោកមេធា[redacted]៊ុនធឿន ។

**-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ: ១៨១៦ "ក" ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖**

១-ទទួលពាក្យបណ្ដឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១៧២ "ក" ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ របស់លោក[redacted] ប៊ុនធឿន ជាមេធាវីការពារសិទ្ធិឲ្យពិរុទ្ធជនឈ្មោះ[redacted]ឧត្តម ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១១៧២ "ក" ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការដដែល លើកលែងតែចំណុចទី១ នៃសេចក្ដីសម្រេច ដែលត្រូវសម្រេចសារជាថ្មី ដូចខាងក្រោម៖

២-១-កែប្រែបទចោទប្រកាន់លើ៖ ឈ្មោះ [redacted] ឧត្តម ហៅ ហុង ភេទប្រុស អាយុ ២១ ឆ្នាំ (មានសាវតារជាតិដូចខាងលើ) ពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ មកបទប្រទូសកេរខ្មាស តាមបញ្ញត្តិមាត្រា ២៤៦ នៃក្រមព្រហ្មទណ្ឌ[redacted]ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ ។

២-២-ផ្ដន្ទាទោសដាក់ពន្ធនាគារលើ៖ ឈ្មោះ [redacted] ឧត្តម ហៅ ហុង ភេទប្រុស អាយុ ២១ ឆ្នាំ (មានសាវតារជាតិដូចខាងលើ) កំណត់រយៈពេល ០៣ឆ្នាំ(បីឆ្នាំ) គិតចាប់ពីថ្ងៃចាប់ខ្លួនបានយកមកអនុវត្តទោសក្នុងពន្ធនាគារ ពីបទ ប្រទូសកេរខ្មាស តាមបញ្ញត្តិមាត្រា ២៤៦ នៃក្រមព្រហ្មទណ្ឌ ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ ត្រូវនឹងថ្ងៃចន្ទ ១៤កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ចំពោះមុខពិរុទ្ធជនឈ្មោ[redacted]ឧត្តម ។

ទុកសិទ្ធិប្ដឹងឧទ្ធរណ៍ តាមកាលកំណត់នៃច្បាប់ ។

-បានឃើញៈ សេចក្តីសុំប្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ឧត្តម ហៅ ហុង ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ១៨១៦ "ក" ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តរបស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុច សេចក្តីសម្រេចទាំងមូលរបស់សាលក្រម ។

-បានឃើញៈ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ។

-បានឃើញៈ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ ។

## នាពេលសវនាការ

## ប្រធានក្រុមប្រឹក្សាជំនុំជម្រះសង្ខេបរបាយការណ៍រឿង

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះប្រាប់សិទ្ធិដល់ជនជាប់ចោទ ។

-ជនជាប់ចោទឈ្មោះ [redacted]ឧត្តម ហៅ ហុង (វត្តមាន)

-ជនរងគ្រោះឈ្មោះ [redacted]មហុង (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]សីហា (វត្តមាន)

-លោក [redacted] ប៊ុនធឿន និងលោក [redacted]សុខា មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] ឧត្តម ហៅ ហុង បានឆ្លើយថាៈ ខ្លួនប្តឹងឧទ្ធរណ៍មកនេះ គឺខ្លួនមិនបានប៉ុនប៉ងរំលោភគេទេ ។ ខ្លួនចូលទៅក្នុងបន្ទប់ ខ្លួនស្មានតែប្រពន្ធរបស់ខ្លួន តែដល់ពេលចូលទៅប៉ះប្អូន ពេលខ្លួនប្អូនក៏ស្រែក ហើយខ្លួនក៏បានចេញមកវិញ ។ ក្រោយមកប៉ាម៉ាក់ក្មេកគាត់ដឹង គាត់បានឱ្យខ្លួនធ្វើកំណត់ហេតុឱ្យគាត់មួយ ហើយខ្លួន ព្រមទាំងឪពុកម្តាយរបស់ខ្លួនផ្តិតមេដៃ ។ គាត់ថា គាត់មិនយកទោសពៃអីទេ ព្រោះខ្លួនរស់នៅក្នុងគ្រួសារគាត់ ។ ក្រោយមកបន្ទាប់ពីខ្លួនបានលែងលះជាមួយប្រពន្ធខ្លួនបានជាក់ស្រេច កន្លងបានកន្លះខែ ទើបគាត់យករឿងហ្នឹងមកប្តឹងខ្លួនវិញ ។ ខ្លួនអត់បានដើរនិយាយដើមគាត់ទេ ។ នៅសាលាដំបូងគាត់ថា គាត់មិនចង់ប្តឹងខ្លួនទេ តែមកពីម៉ាក់ខ្លួនដើរនិយាយដើមគាត់ ។ ខ្លួនគ្រាន់ប៉ះជនរងគ្រោះពីក្រោយខ្នង ។ នៅថ្ងៃកើតហេតុ ខ្លួនដេកនៅបន្ទប់ជាប់គ្នា ដែលជាបន្ទប់ខ្លួន ។ ខ្លួនធ្វើកំណត់ហេតុព្រោះពេលនោះ ប៉ាក្មេកគាត់ថា បើមិន ធ្វើគាត់ប្តឹងគេឱ្យចាប់ខ្លួន ។ គេចាប់រូបខ្លួន ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ ។ ខ្លួនអត់បានស្រាតខោ យកប្រដាប់ភេទដាក់ទល់ប្រដាប់ភេទគេដែរ ។ សូមតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted] គឹមហុង បានឆ្លើយថាៈ ថ្ងៃកើតហេតុប៉ាខ្លួនទៅហែរទានវស្សា ខ្លួននៅផ្ទះជាមួយពូ យាយ បងស្រី និងគាត់(ជនជាប់ចោទ) ។ ដល់ពេលទាបភ្លឺម៉ាក់ប៉ារបស់ខ្លួនចេញទៅហែរទានវស្សាតាំងពីម៉ោង ៣ ភ្លឺ ។ ហើយប៉ាខ្លួនអត់បានចាក់សោរបន្ទប់ខ្លួនទេ ហើយគាត់(ជនជាប់ចោទ) ក៏បានចូលក្នុងបន្ទប់ខ្លួន ។ នៅថ្ងៃកើតហេតុនោះខ្លួនស្លៀកខោអាវគេងយប់ ខ្លួនគេងម្នាក់ឯង គេបែរខ្នង ។ បន្ទប់ខ្លួនបិទភ្លើង ពេលគាត់(ជនជាប់ចោទ)ចូលមក គាត់(ជនជាប់ចោទ) ប៉ះខ្លួនហើយ គាត់ថើបកខ្លួន ។ ពេលខ្លួនស្រែកគាត់(ជនជាប់ចោទ)ខ្ទប់មាត់ខ្លួន ហើយគាត់ទាញសំលៀក

បំពាក់ខ្លួនចេញ ។ គាត់(ជនជាប់ចោទ) យកប្រដាប់ភេទរបស់គាត់ដាក់ចូលក្នុងប្រដាក់ភេទញ៉ុល ប្រដាប់ភេទរបស់ខ្លួន តែខ្លួនបានចាក់ចំប្រដាក់ភេទរបស់គាត់(ជនជាប់ចោទ) ហើយគាត់ក៏គំរាមមកឱ្យខ្លួនប្រាប់ប៉ា បើប្រាប់នឹងដឹងគ្នាជាមួយគាត់(ជនជាប់ចោទ) ហើយ ។ ពេលដែលខ្លួនស្រែកនោះ អ៊ុំខ្លួនបានឮពេលស្រែកឡើងអ៊ុំខ្លួនសួរ ខ្លួនក៏ប្រាប់ថា គាត់(ជនជាប់ចោទ) ចាប់រំលោភខ្លួន តែខ្លួនមិនហ៊ានប្រាប់អ៊ុំខ្លួនថា គាត់(ជនជាប់ចោទ) ដាក់ប្រដាក់ភេទញ៉ុលប្រដាក់ភេទរបស់ខ្លួនទេ ព្រោះពេលនោះខ្លួនភ័យពេក ។ ខ្លួនឆ្លើយនេះ ជាពាក្យពិត ព្រោះគាត់(ជនជាប់ចោទ) បានធ្វើចឹងដាក់ខ្លួនមែន ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីហា បានឆ្លើយថាៈ កាលហ្នឹងខ្លួនទៅហែរទានវស្សាដោយទុកឱ្យកូននៅផ្ទះ ឱ្យនៅជាមួយម៉ាវ៉ា (ម្តាយក្មេកខ្លួន) ព្រោះខ្លួនទៅហែរទានវស្សាដល់ខេត្តព្រះវិហារ ។ ពេលត្រឡប់មកវិញ ខ្លួនក៏អត់ទាន់បានដឹងដែរ ព្រោះខ្លួនទៅធ្វើការនៅឆ្ងាយ ។ ក្រោយមកទៀតបានកូនខ្លួនជាបងបានមកប្រាប់ ហើយសុំទោស ។ ពេលនោះខ្លួនក៏ហៅជនជាប់ចោទមកសួរ ហើយគេក៏ថា ចឹងមែន ។ ខ្លួនគិតថា បើបានជាគ្រួសារហើយ បើផ្សព្វផ្សាយខ្មាស់គេ ចឹងមានតែទ្រាំ ឱ្យគេកែខ្លួនទៅ ហើយខ្លួនក៏ឱ្យធ្វើកិច្ចសន្យាហៅឪពុកម្តាយមកផ្តិតមេដៃទទួលស្គាល់ ហើយមើលកូនផងកុំឱ្យធ្វើចឹងទៀត បើឮទៅក្រៅខ្មាស់គេ ព្រោះខ្លួនធ្វើការមន្ត្រី រាជការដែរ ។ តែបុគ្គលនេះមិនរាងចាល ហើយក៏កើតជាទំនាស់ប្តីប្រពន្ធគេ បន្ទាប់មកក៏បានលែងគ្នា ។ ហើយខ្លួនទ្រាំព្រោះគិតថា ជាកូនជាចៅហើយ ចឹងមានតែទ្រាំ ។ តែឪពុកម្តាយគេ ក៏បានទៅបរិហារកេរ្តិ៍ទៀត ។ ដោយទ្រាំមិន ខ្លួនក៏ដាក់ពាក្យបណ្តឹងតែម្តងទៅ ។ ខ្លួនស្នើសុំតុលាការផ្តន្ទាទោសលើជនជាប់ចោទ ៨ ឆ្នាំ និងពិន័យជាប្រាក់ ៥ម៉ឺនដុល្លារ ។

-តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន ដោយយល់ឃើញថា ការសម្រេចសេចក្តីរបស់សាលាដំបូងខេត្តបាត់ដំបង ដែលសម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ឧត្តម ហៅ ហ៊ុង កំណត់រយៈពេល ០៣ (បី) ឆ្នាំ ពីបទ ប្រទូសកេរខ្មាស គឺជាការត្រឹមត្រូវតាមកំណត់ច្បាប់ ហេតុដូច្នេះគប្បីតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៨១៦ (ក) ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការដដែល ។ តំណាងមហាអយ្យការសន្និដ្ឋានឲ្យក្រុមប្រឹក្សាជំនុំជម្រះសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បាត់ដំបង គប្បីពិចារណា និងសម្រេចតាមការយល់ឃើញខាងលើ ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដានថា នៅក្នុងសំណុំរឿងនេះពាក់ព័ន្ធនឹងការចោទប្រកាន់មកលើកូនក្តីខ្លួន មិនមានអ្វីផ្សេងក្រៅតែពីចម្លើយជនរងគ្រោះ និងកិច្ចសន្យានោះទេ ។ ចម្លើយរបស់ជនរងគ្រោះ មានការប្រែប្រួលជាច្រើនលើកច្រើនសារ ។ ម៉្យាងទៀតទាក់ទងនឹងកិច្ចសន្យាដែលធ្វើឡើងដោយជនជាប់ចោទ ជាមួយដើមបណ្តឹងរដ្ឋប្បវេណី គឺហាក់បីដូចជាបោកបញ្ឆោតឱ្យជនជាប់ចោទ ធ្វើដាក់បន្ទុកលើខ្លួនឯង ។ អង្គហេតុនេះកើតតាំងពីឆ្នាំ២០១៧

តែទើបមកប្តឹងឆ្នាំ២០១៩ បានគម្លាតនេះ មានរយៈពេលយូរដែរ បន្ទាប់ពីគ្រួសារទាំងពីរលែងមានទំនាក់ទំនងញាតិហ្នឹងគ្នាហើយ ដែលចូលជាលក្ខណៈគំនុំគ្រួសារទៅវិញ ។ នៅក្នុងការចោទប្រកាន់ទោះបីមានចម្លើយជនរងគ្រោះ ដែលចោទប្រកាន់ជនជាប់ចោទ តុលាការក៏ត្រូវសម្រេចដោយផ្អែកតាមភស្តុតាងផ្សេងៗទៀត ដើម្បីរកពិរុទ្ធភាពរបស់ជនជាប់ចោទ ។ ម៉្យាងទៀតកូនក្តីរបស់ខ្លួនក៏មិនបានសារភាពទៀត ណាមួយជាតុអត្តនោម័ត កូនក្តីរបស់ខ្លួនមិនមានចេតនាក្នុង ការប្រព្រឹត្តនៅបទល្មើសនេះទេ ដូចការលើកឡើងរបស់គាត់ ដោយគាត់ថា យល់ច្រលំស្មានតែជាប្រពន្ធរបស់គាត់ ។ ដោយចំពោះការចាប់ខ្លួនរបស់កូនក្តីខ្លួន តុលាការបានចាប់ខ្លួននៅពេលសវនាការ ។ តាំងពីដំណាក់កាលសមត្ថកិច្ច ដល់ចៅក្រមស៊ើបសួរ គាត់ចូលឆ្លើយរហូត មិនបានគេចខ្លួនទេ ។ ចឹងការផ្តន្ទាទោសកូនក្តីខ្លួន ពីបទ ប្រទូសកេរ្តិ៍ គឺផ្តន្ទាទោសក្នុងកម្រិតអតិបរមាទៅហើយ ។ អ្វីដែលជាកំហុសរបស់គាត់គឺគាត់បានសារភាពហើយ ។ ភស្តុតាងដែលដាក់បន្ទុកលើកូនក្តីខ្លួន គឺមានតែចម្លើយរបស់ជនរងគ្រោះនិងដើមបណ្តឹងតែប៉ុណ្ណោះ គឺមិនបានពិចារណានូវចម្លើយរបស់កូនក្តីខ្លួនបានឆ្លើយទេ ។ កូនក្តីខ្លួនបានឆ្លើយបដិសេធថា មិនមានការប៉ុនប៉ងរំលោភសេពសន្ថវៈទេ គឺកូនក្តីខ្លួនគ្រាន់តែប៉ះពីក្រោយព្រោះស្មានតែជាប្រពន្ធរបស់ខ្លួន ។ ចម្លើយ និងភស្តុតាង មិនមានភាពស៊ីសង្វាក់គ្នា ។ ម៉្យាងទៀតការកែប្រែពី បទ ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោស មកជាបទ ប្រទូសកេរ្តិ៍ តាមមាត្រា ២៤៦ នៃក្រមព្រហ្មទណ្ឌ ។ ចំណែកជនរងគ្រោះក៏មិនបានប្តឹងឧទ្ធរណ៍ដែរ ។ ខ្លួនស្នើសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន ដោយផ្តន្ទាទោស ១ ឆ្នាំ ត្រឹមកម្រិតអប្បរមា នៃមាត្រា ២៤៦ នៃក្រមព្រហ្មទណ្ឌ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ។
-ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះ ។
-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី ។
-ក្រោយពីបានស្តាប់សំណូមពររបស់ជនជាប់ចោទ ។
-ក្រោយពីបានស្តាប់សំណូមពររបស់ដើមបណ្តឹងរដ្ឋប្បវេណី ។
-ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ ។
-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សាលាឧទ្ធរណ៍បាត់ដំបង

## យល់ឃើញថា

១.ពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់ឈ្មោ[redacted]ឧត្តម ហៅ ហ៊ុង ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍បាត់ដំបង ទទួលជំនុំជម្រះបានយោងតាមបញ្ញត្តិមាត្រា ៣៨២ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២.ជនជាប់ចោទឈ្មោះ[redacted]ឧត្តម បានឆ្លើយបញ្ជាក់ថា ខ្លួនពុំបានប្រព្រឹត្តអំពើ ប៉ុនប៉ងរំលោភសេពសន្ថវៈលើឈ្មោ[redacted]ហុង ដែលជាប្អូនថ្លៃស្រីរបស់ខ្លួននោះទេ ។ នៅថ្ងៃកើតហេតុខ្លួនពិតជាបានចូលទៅអោបឈ្មោ[redacted]ហុង ពីក្រោយមែននៅក្នុងបន្ទប់របស់យាយ ដោយខ្លួនស្មានថាប្រពន្ធរបស់ខ្លួនក្នុងគោលបំណងលួងលោមប្រពន្ធខ្លួនដែលបានឈ្លោះប្រកែកគ្នា ។ ប៉ុន្តែតាមកំណត់ហេតុទទួលស្គាល់កំហុស ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ បានបញ្ជាក់ថាជនជាប់ចោទរូបនេះ ទទួលស្គាល់កំហុសខ្លួនដែលបានចាប់ប្អូនថ្លៃស្រីប៉ុនប៉ងរំលោភសេពសន្ថវៈ ។

៣.ជនរងគ្រោះឈ្មោះ ត្រ[redacted]ហុង បានបញ្ជាក់ថាឈ្មោះ[redacted] ឧត្តម បានចូលក្នុងបន្ទប់ខ្លួនគេងតែឯងម៉ោង ០៥ ភ្លឺ ។ ឈ្មោះ ថ[redacted]ឧត្តម បានចាប់អោបថើប ហើយខ្ទប់មាត់ខ្លួនកុំឲ្យឲ្យស្រែក ហើយបានចាប់ស្រាតខោខ្លួន ។ យប់កើតហេតុខ្លួនបានស្រែកដែរតែមិនមានអ្នកលឺដោយសារឈ្មោះ[redacted] ឧត្តម បានយកខ្នើយខ្ទប់មាត់ខ្លួន។ ឈ្មោះ ថន [redacted]ាប់ទាញខ្លួនធ្លាក់ពីលើគ្រែ តែធ្លាក់តែជើង[redacted] ខ្លួនដឹងថាឈ្មោះ [redacted]ន ឧត្តម ចាប់ដោយសារខ្លួនចាំក្លិនទឹកអប់ និងសម្លេងគាត់ដែលបានគំរាមខ្លួនថាកុំស្រែក ។ ឈ្មោះ[redacted]ឧត្តម បានយកប្រដាប់ភេទរបស់គាត់ដាក់ចូលប្រដាប់ភេទរបស់គាត់ដាក់ចូលប្រដាប់ភេទរបស់ខ្លួនបានបន្តិច តែខ្លួនធាក់វាចេញ ។

៤.តាមចម្លើយរបស់ជនជាប់ចោទ តាមចម្លើយរបស់ជនរងគ្រោះ និងតាមកំណត់ហេតុទទួលស្គាល់កំហុស ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ បានបញ្ជាក់ឲ្យឃើញថាជនជាប់ចោទឈ្មោះ[redacted]ឧត្តម ពិតជាបានចាប់ជនរងគ្រោះឈ្មោះ គ្រី[redacted]ន្ថវៈ ប្រាកដមែន ។

៥.តំណាងមហាអយ្យការបានធ្វើសេចក្ដីសន្និដ្ឋាន ដោយយល់ឃើញថា ការសម្រេចសេចក្ដីរបស់សាលាដំបូងខេត្តបាត់ដំបង ដែលសម្រេចផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ[redacted]ឧត្តម ហៅ ហ៊ុង កំណត់រយៈពេល ០៣ (បី) ឆ្នាំ ពីបទ ប្រទូសកេរខ្មាស គឺជាការត្រឹមត្រូវតាមកំណត់ច្បាប់ ហេតុដូច្នេះគប្បីតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៨១៦ (ក) ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបាត់ដំបងទុកជាបានការដដែល ។ តំណាងមហាអយ្យការសន្និដ្ឋានឲ្យក្រុមប្រឹក្សាជំនុំជម្រះសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បាត់ដំបង គប្បីពិចារណា និងសម្រេចតាមការយល់ឃើញខាងលើ ។

៦.អំពើរបស់ជនជាប់ចោទឈ្មោះ ថ[redacted]ឧត្តម ហៅ ហ៊ុង ជាអំពើប៉ុនប៉ងរំលោភសេពសន្ថវៈ ហើយការដែលសាលាដំបូងខេត្តបាត់ដំបង សម្រេចកែប្រែបទចោទប្រកាន់ និងផ្ដន្ទាទោសលើជនជាប់ចោទពីបទប្រទូសកេរខ្មាស គឺពុំមានលក្ខណៈត្រឹមត្រូវឡើយ ប៉ុន្តែអយ្យការក៏ដូចជាមហាអយ្យការពុំបានប្ដឹងឧទ្ធរណ៍ ដូច្នេះសាលាឧទ្ធរណ៍បាត់ដំបង ពុំអាចសម្រេចតម្លើងទោសលើជនជាប់ចោទបានឡើយ ដូច្នេះគប្បីសម្រេច

រក្សាការផ្តន្ទាទោសដដែលដោយគ្រាន់តែកែប្រែបទចោទប្រកាន់ពីបទ ប្រទូសកេរខ្មាស មកជាបទ ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសវិញ ដើម្បីជាប្រយោជន៍ច្បាប់ ។

**<u>ហេតុដូច្នេះវិនិច្ឆ័យសេចក្តី</u>**

១/ ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់ឈ្មោះ [redacted]ឧត្តម ហៅ ហ្វុង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២/ តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៨១៦ "ក" ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការដដែល ដោយគ្រាន់តែបដិសេធចំណុចទី២-១ ចោល និងកែប្រែបទចោទប្រកាន់ក្នុងចំណុចទី២-២ ពីបទ ប្រទូសកេរខ្មាស មកជាបទ ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនងរងគ្រោះវិញ ។ ចំណុចក្រៅពីនេះរក្សាទុកជាបានការដដែល ។

៣/ សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |